# អនុស្សរណៈយោគយល់គ្នា

# ស្តីពី

# កិច្ចសហប្រតិបត្តិការ អំពីកម្មសិទ្ធិឧស្សាហកម្ម

# រវាង

# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

# និង

# អគ្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី

ក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរីនៃសាធារណរដ្ឋសិង្ហបុរី៖

- ដោយយល់ឃើញអំពីតម្លៃ និងសារសំខាន់នៃកម្មសិទ្ធិឧស្សាហកម្មសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងការផ្លាស់ប្តូរបច្ចេកទេស
- ដោយពិចារណាដល់សេចក្តីត្រូវការដើម្បីជំរុញធ្វើឲ្យប្រសើរឡើង និងពង្រឹងប្រព័ន្ធកម្មសិទ្ធិឧស្សាហកម្មក្នុងទិដ្ឋភាពផ្តល់នូវការឆ្លើយតបដ៏មានប្រសិទ្ធភាពទៅនឹងភាពប្រឈមទាំងឡាយដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិជ្ជាថ្មី
- ដោយយល់ឃើញសម្រាប់អភិវឌ្ឍន៍បន្ថែមទៀតនូវសហប្រតិបត្តិការរវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ភាគីនីមួយៗចាប់ពីពេលនេះតទៅចាត់ទុកជា "**ភាគី**" ហើយភាគីទាំងពីរចាត់ទុកជា"**គូភាគី**"។ ដើម្បីដោះស្រាយបញ្ហាប្រឈមនៃសតវត្សនេះ និងជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ច រវាងកម្ពុជា និងសិង្ហបុរី
- ដោយគិតពិចារណាទៅដល់ទំហំនៃការអភិវឌ្ឍន៍កម្មសិទ្ធិឧស្សាហកម្ម
- បានព្រមព្រៀងនូវចំណុចដូចខាងក្រោម៖

## ប្រការ១
## កម្មវត្ថុ

អនុស្សរណៈយោគយល់គ្នារវាងប្រទេសកម្ពុជា និងសិង្ហបុរីគឺជាការកើតឡើងពីកម្មវត្ថុរួមរបស់គូភាគីក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ស្តីពីកម្មសិទ្ធិឧស្សាហកម្ម។

## ប្រការ២
## សាវតា

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាក្រសួងដែលបានបង្កើតដោយព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣។ អនុក្រឹត្យលេខ ៥៧៥.អនក្រ.បក ចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានកំណត់ឲ្យ ក្រសួងនេះទទួលបន្ទុកក្នុងការគ្រប់គ្រងអភិវឌ្ឍ និងការជំរុញឧស្សាហកម្ម និងសិប្បកម្មសហគ្រាសធុនតូច និងមធ្យម កម្មសិទ្ធិឧស្សាហកម្ម និងការច្នៃប្រឌិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី គឺជាស្ថាប័នដែលស្ថិតក្រោមឱវាទក្រសួងយុត្តិធម៌ ចាប់តាំងពីខែ មេសា ឆ្នាំ ២០០១ ជាស្ថាប័ននាំមុខក្នុងការផ្តល់យោបល់ និងគ្រប់គ្រងអំពីច្បាប់កម្មសិទ្ធិបញ្ញា ជំរុញការផ្សព្វផ្សាយកម្មសិទ្ធិបញ្ញា និងផ្តល់ចេនាសម្ព័ន្ធដើម្បីសម្រួលដល់ការអភិវឌ្ឍន៍កម្មសិទ្ធិ បញ្ញានៅប្រទេសសិង្ហបុរី។ អង្គភាព

កម្មសិទ្ធិបញ្ញាសិង្ហបុរី ក្នុងនាមជានិយតករកម្មសិទ្ធិបញ្ញា និងជាអ្នក ផ្តល់ប្រឹក្សាផ្នែកគោលនយោបាយត្រូវបាន សន្យាទ្រទ្រង់ឲ្យបានរឹងមាំ ផ្អែកលើរបបកម្មសិទ្ធិបញ្ញាសម្រាប់ការពារ និងការធ្វើពាណិជ្ជកម្មអាជីវកម្ម។

## ប្រការ៣
## កិច្ចសហប្រតិបត្តិការបរច្ចេកទេស

១. គូភាគីនឹងធ្វើកិច្ចសហប្រតិបត្តិការលើផ្នែកដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដូចខាងក្រោម៖

- ក. អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ទទួលពាក្យសុំប្រកាសនីយបត្រតក្កកម្ម និងបំពេញ តួនាទីជា អាជ្ញាធរស្រាវជ្រាវ និងពិនិត្យពាក្យសុំប្រកាសនីយបត្រតក្កកម្ម ជំនួសក្រសួង ឧស្សាហកម្ម និង សិប្បកម្ម
- ខ. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលពាក្យសុំប្រកាសនីយបត្រតក្កកម្ម ជំនួស អង្គភាពកម្ម សិទ្ធិបញ្ញាសិង្ហបុរី
- គ. អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ទទួលពាក្យសុំគំនូរឧស្សាហកម្ម ជំនួសក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ឃ. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលពាក្យសុំគំនូរឧស្សាហកម្ម ជំនួសអង្គភាព កម្មសិទ្ធិបញ្ញាសិង្ហបុរី
- ង. ធ្វើឲ្យមានការចុះសម្រុងនឹងគ្នានូវនីតិវិធី និងបែបបទរបស់ការិយាល័យទាំងពីរ
- ច. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ ដោយអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី និងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីដោយអង្គភាព កម្មសិទ្ធិបញ្ញាសិង្ហបុរី
- ឆ. អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មដែលបានផ្តល់ដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំពោះប្រកាសនីយបត្រតក្កកម្មណាដែលអង្គភាព កម្មសិទ្ធិបញ្ញាសិង្ហបុរីបានបំពេញតួនាទីជាអាជ្ញាធរស្រាវជ្រាវ និងពិនិត្យ
- ជ. ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងប្រមូលកំរៃសេវា ជំនួសឲ្យអង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី
- ឈ. អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី នឹងប្រមូលកំរៃសេវាជំនួសឲ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម

២. គូភាគីយល់ព្រមផងដែរ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការចំពោះកម្មវត្ថុដូចខាងក្រោម៖

- ក. បណ្តុះបណ្តាលមន្ត្រី នឹងផ្លាស់ប្តូរការអនុវត្តន៍ល្អបំផុត បទពិសោធន៍ និងចំណេះដឹងអំពី ការគ្រប់គ្រង និងការការពារកម្មសិទ្ធិឧស្សាហកម្ម ជាពិសេសនៅក្នុងផ្នែកដូចតទៅ៖ ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម ការការពារពូជរុក្ខជាតិ និងគំនូសបង្ហាញនៃ សៀគ្វី បង្រួម

ខ. ផ្លាស់ប្តូរការអនុវត្តន៍ល្អបំផុត បទពិសោធន៍ និងចំណេះដឹងអំពីតួនាទីរបស់គូភាគីក្នុងការ ពន្លឿន និងជំរុញការច្នៃប្រឌិតក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្ម

គ. ផ្លាស់ប្តូរការអនុវត្តន៍ល្អបំផុត បទពិសោធន៍ និងចំណេះដឹងអំពីតួនាទីរបស់គូភាគីក្នុងការ លើកទឹកចិត្តឧស្សាហកម្ម ឲ្យប្រើប្រាស់កម្មសិទ្ធិឧស្សាហកម្ម ដើម្បីសម្រួលការអភិវឌ្ឍន៍ សេដ្ឋកិច្ច និង

ឃ. សហការបណ្តុះបណ្តាល អំពីកម្មសិទ្ធិឧស្សាហកម្ម ដល់អ្នកពាក់ព័ន្ធនឹងផ្នែកកម្មសិទ្ធិ ឧស្សាហកម្ម និងសហគមន៍ពាណិជ្ជកម្មក្នុងស្រុក។

៣. សកម្មភាពសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ នឹងត្រូវយកមកអនុវត្តតាមរយៈ ការផ្លាស់ប្តូរបេសកកម្មជាន់ខ្ពស់ បេសកកម្មបច្ចេកទេស កម្មវិធីការងារ និងមធ្យោបាយផ្សេងទៀតដែល នឹងមានការយល់ព្រមដោយគូភាគី។

៤. គូភាគីនឹងយល់ព្រម៖

ក. សហការរៀបចំខ្លឹមសារ ប្រធានបទ កាលបរិច្ឆេទ និងកិច្ចការលម្អិតផ្សេងទៀតនៃបេសកម្មបច្ចេកទេស កម្មវិធីការងារ និងសកម្មភាពសហប្រតិបត្តិការផ្សេងទៀតដែលស្ថិតនៅក្រោមអនុស្សរណៈយោគយល់គ្នានេះ តាមរយៈផែនការការងារដែលនឹងត្រូវយល់ព្រមដោយគូភាគី។

ខ. ពិនិត្យលទ្ធភាពពង្រីកកិច្ចសហប្រតិបត្តិការនេះទៅដល់ប្រភេទផ្សេងទៀតនៃកម្មសិទ្ធិបញ្ញា

គ. រៀបចំ និងយល់ព្រមទៅលើកម្រៃសេវាដែលតម្រូវដូចមានចែងក្នុងមាត្រា ៣

ឃ. អញ្ជើញការិយាល័យកម្មសិទ្ធិបញ្ញាអាស៊ានផ្សេងទៀត ឲ្យចូលរួមតាមគំរូកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ និង

ង. ពិចារណាទទួលស្គាល់អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី ជាអាជ្ញាធរអន្តរជាតិមានសមត្ថកិច្ចស្រាវជ្រាវ និងពិនិត្យ បន្ទាប់ពីកម្ពុជាក្លាយជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម

៥. គ្រប់សកម្មភាពសហប្រតិបត្តិការអនុស្សរណៈយោគយល់គ្នានេះ នឹងអាចអនុវត្តបានអាស្រ័យលើ លទ្ធភាពនៃធនធានរបស់ភាគីនីមួយៗ។

## ប្រការ៧
## វិសោធនកម្ម

អនុស្សរណៈយោគយល់គ្នានេះអាចធ្វើវិសោធនកម្មបាន លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគូភាគី។

## ប្រការ៨
## លក្ខណៈច្បាប់

អនុស្សរណៈយោគយល់គ្នានេះ និងសកម្មភាពនៃសហប្រតិបត្តិការក្រោមអនុស្សរណៈយោគ យល់គ្នានេះអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាននៃភាគីនីមួយៗ។ អនុស្សរណៈយោគយល់គ្នានេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗក្រោមកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ផ្សេងទៀតដែលភាគីនោះត្រូវបានជាប់កិច្ចសន្យានោះទេ។

## ប្រការ៩
## ការកំណត់ពេលវេលានៃការពិនិត្យឡើងវិញ

គូភាគីនឹងកំណត់ពេលវេលានៃការពិនិត្យឡើងវិញ ដើម្បីវាយតម្លៃទៅលើកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ មុនដំណាច់ឆ្នាំទីមួយនៃអនុស្សារណៈនេះចូលជាធរមាន។

## ប្រការ១០
## រយៈពេល និងការបញ្ចប់

១. អនុស្សរណៈយោគយល់គ្នានេះ ចូលជាធរមានចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាដោយគូភាគី ហើយ នឹងត្រូវបញ្ចប់រយៈពេលប្រាំ (៥) ឆ្នាំ។

២. ភាគីនីមួយៗអាចបញ្ចប់អនុស្សរណៈយោគយល់គ្នានេះ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីមួយទៀតយ៉ាងតិចមុនរយៈពេលសាបសិប (៣០)ថ្ងៃ។

៣. មុនពេលផុតកំណត់ ឬបញ្ចប់អនុស្សរណៈយោគយល់គ្នានេះ គូភាគីនឹងពិគ្រោះយោបល់គ្នាទៅវិញទៅ មក ហើយបញ្ជាក់ជាលាយលក្ខណ៍អក្សរ ថាតើមានបំណងបន្តសកម្មភាពកិច្ចសហប្រតិបត្តិការដែលកំពុង ដំណើរការក្នុងអំឡុងកាលបរិច្ឆេទផុតកំណត់ ឬបញ្ចប់អនុស្សរណៈយោគយល់គ្នានេះតែម្តង។

## ប្រការ៤
## ធនធានហិរញ្ញវត្ថុ

ការអនុវត្តន៍សកម្មភាពសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះដោយភាគីនីមួយៗ (រាប់បញ្ចូលទាំងការចំណាយសម្រាប់ការធ្វើដំណើរ ការស្នាក់នៅ ការចំណាយប្រចាំថ្ងៃរបស់បុគ្គលិកដែល ពាក់ព័ន្ធនឹងសកម្មភាពនេះ) គឺអាស្រ័យលើ (i) លទ្ធភាពហិរញ្ញវត្ថុ និងថវិកាអាទិភាពរបស់ភាគីនីមួយៗ និង (ii) ការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយគូភាគី។

## ប្រការ៥
## មន្ត្រីដែលត្រូវចាត់តាំង

ចំពោះមន្ត្រីដែលបានចាត់តាំងដោយភាគីណាមួយ ដើម្បីអនុវត្តសកម្មភាពសហប្រតិបត្តិការក្រោម អនុស្សរណៈយោគយល់គ្នានេះ នឹងស្ថិតនៅតែក្រោមការចង្អុលបង្ហាញ និងដឹកនាំរបស់ភាគីនោះ ដោយ គ្មានការបង្កើតទំនាក់ទំនងការងារថ្មីដែលបង្កើតឡើងរវាងមន្ត្រីនោះ និងភាគីផ្សេងទៀតឡើយ។ គ្មានភាគី ណានឹងត្រូវបានចាត់ទុកជានិយោជកជំនួសមន្ត្រីណាមួយនៃភាគីផ្សេងទៀតបានឡើយ។

## ប្រការ៦
## អ្នកសម្របសម្រួលសកម្មភាព

១. គូភាគីនឹងចាត់តាំងអ្នកសម្របសម្រួលរៀងៗខ្លួន ដើម្បីទទួលបន្ទុកការអនុវត្តន៍ត្រួតពិនិត្យ និងវាយ តម្លៃសកម្មភាពកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ។ អ្នកសម្របសម្រួលខាងលើ នេះនឹងធ្វើទំនាក់ទំនងបឋមសម្រាប់គ្រប់ការទំនាក់ទំនងរវាងគូភាគី និងសម្របសម្រួលសកម្មភាព សហប្រតិបត្តិការទាំងអស់ក្រោមអនុស្សរណៈយោគយល់គ្នានេះ។

២. គូភាគីនឹងរៀបចំឲ្យមានឱកាសសម្រាប់មន្ត្រីជួបប្រជុំ និងពិភាក្សាអំពីប្រធានបទសំខាន់ៗតាមពេល វេលាសមស្រប។ ការរៀបចំនេះរាប់បញ្ចូលទាំងការអញ្ជើញបុគ្គលិករបស់ភាគីមួយពីសំណាក់ភាគីមួយទៅ បុគ្គលិកនៃភាគីមួយទៀតដើម្បីទស្សនកិច្ចការិយាល័យរបស់ខ្លួន។

## ប្រការ១១
## ការពិគ្រោះយោបល់

ភាគីនឹងពិគ្រោះយោបល់គ្នាតាមការសមស្រប អំពីការអនុវត្តន៍អនុស្សរណៈយោគយល់គ្នានេះ។

## ប្រការ១២
## ភាសា

អនុស្សរណៈយោគយល់គ្នានេះត្រូវធ្វើឡើងបួនច្បាប់ជាច្បាប់ដើមដែលមានខ្លឹមសារដូចគ្នា ដែលពីរច្បាប់ជាភាសាអង់គ្លេស និងពីរច្បាប់ជាភាសាខ្មែរ។ ក្នុងករណីមានភាពមិនចុះសម្រុងគ្នា ឬខ្វែងគំនិតគ្នាលើការបកស្រាយរវាងអត្ថបទជាភាសាអង់គ្លេស និងភាសាខ្មែរនៃអនុស្សារណៈយោគយល់គ្នានេះ អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាមូលដ្ឋាន។

ធ្វើនៅ សិង្ហបុរី ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ឯកឧត្តម ចម ប្រសិទ្ធ**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី**

**លោក តាន់ យី សាន**

ប្រធានប្រតិបត្តិ

អង្គភាពកម្មសិទ្ធិបញ្ញាសិង្ហបុរី